**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកំពង់ស្ពឺ**
លេខ:១០៩/២១.សរ.ណ

ថ្ងៃពុធ ១២ កើត ខែ ផល្គុន ឆ្នាំ ជូត ទោស័ក ព.ស.២៥៦៤
កំពង់ស្ពឺ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០២១....

## <u>ជម្រាបមក</u>

### លោកអភិបាល នៃគណៈអភិបាលក្រុង និងស្រុកទាំង៨

**កម្មវត្ថុ** ៖ ស្តីពីការផ្អាកជាបណ្តោះអាសន្ន នូវកម្មវិធីអាពាហ៍ពិពាហ៍ ពិធីជប់លៀង និងពិធីជួបជុំផ្សេងៗ។
**យោង** ៖ ស្ថានភាពចាំបាច់ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបមក **លោកអភិបាលក្រុង និងស្រុក** មេត្តាជ្រាបថា ដោយស្ថានភាពបច្ចុប្បន្នជំងឺកូវីដ-១៩ ពាក់ព័ន្ធព្រឹត្តិការណ៍ថ្ងៃទី២០ កុម្ភៈ បាននិងកំពុងរីករាលដាលក្នុងសហគមន៍គួរឱ្យព្រួយបារម្ភ ដូចនេះដើម្បីចូលរួមទប់ស្កាត់ បង្ការការពារ ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩នេះ សូម **លោកអភិបាលក្រុង និង ស្រុក** ធ្វើការផ្សព្វផ្សាយណែនាំដល់បងប្អូនប្រជាពលរដ្ឋនៅតាមបណ្តាភូមិ ឃុំ សង្កាត់ឱ្យផ្អាកជាបណ្តោះអាសន្ននូវ**កម្មវិធីអាពាហ៍ពិពាហ៍ ពិធីជប់លៀង និងពិធីជួបជុំផ្សេងៗដែលមានមនុស្សចូលរួមច្រើន ចាប់ពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ នេះ** តទៅរហូតដល់មានការជូនដំណឹងជាថ្មី។ ជាមួយគ្នានេះ ត្រូវបន្តណែនាំដល់បងប្អូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានឱ្យបង្កើនការប្រុងប្រយ័ត្នខ្ពស់ ហើយត្រូវអនុវត្តតាមការណែនាំរបស់រាជរដ្ឋាភិបាល និងតាមវិធានរបស់ក្រសួងសុខាភិបាល ជាពិសេសវិធានការ **«៣ កុំ ៣ ការពារ»** ។

អាស្រ័យហេតុនេះ សូម **លោកអភិបាលក្រុង និង ស្រុក** ចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

សូម **លោកអភិបាលក្រុង និង ស្រុក** ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ ។

**អភិបាល នៃគណៈអភិបាលខេត្ត**

** វ៉ី សំណាង**

*ចម្លងជូន៖*
*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-ក្រសួងមហាផ្ទៃ*
*-ក្រសួងសុខាភិបាល*
*(ដើម្បីជូនជ្រាប)*
*-ស្នងការនគរបាលខេត្ត*
*-បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត*
*-តំបន់ប្រតិបត្តិការសឹករងកំពង់ស្ពឺ*
*-មន្ទីរ អង្គភាពជុំវិញខេត្ត*
*(ដើម្បីសហការអនុវត្ត)*
*-ឯកសារ-កាលប្បវត្តិ*